ADB ធនាគារអភិវឌ្ឍន៍អាស៊ី

RRP: CAM 32431-03

# របាយការណ៍ និង អនុសាសន៍

# របស់ប្រធាន

# ជូនចំពោះ

# ក្រុមប្រឹក្សាភិបាល

# ស្តីពី

# សំណើឥណទាន និង ជំនួយបច្ចេកទេសឥតសំណង

# ជូនចំពោះ

# ព្រះរាជាណាចក្រកម្ពុជា

# សម្រាប់អនុកម្មវិធីទី ៣

# នៃ

# កម្មវិធីវិស័យហិរញ្ញវត្ថុ

ខែ សីហា ឆ្នាំ ២០០៥

**សេចក្តីបញ្ជាក់**

ឯកសារនេះត្រូវបានប្រែសម្រួលពីឯកសារដើមជាភាសាអង់គ្លេសដែលជាភាសាផ្លូវការតែមួយគត់របស់ធនាគារអភិវឌ្ឍន៍អាស៊ី។

# សេចក្តីសង្ខេប ស្តីពី ឥណទាន និង កម្មវិធី

| | |
|---|---|
| ឥណវិន្ត | ព្រះរាជាណាចក្រកម្ពុជា |
| សំណើ | សំណើរួមមាន (១) ឥណទានសិទ្ធិដកប្រាក់ពិសេស (SDR) ស្មើនឹង ៦.៧៦៣.000 (១០ លានដុល្លារ) សម្រាប់អនុកម្មវិធីទី ៣ នៃឥណទានកម្មវិធីហិរញ្ញវត្ថុ (FSPL) និង (២) ជំនួយបច្ចេកទេសឥតសំណងក្នុងទឹកប្រាក់ចំនួន 0,៥ លានដុល្លារ ដើម្បីគាំទ្រការអនុវត្តន៍អនុកម្មវិធី ៣។ FSPL អនុវត្តវិធីសាស្ត្រជាចង្កោម និង រួមមានអនុកម្មវិធីបន្តបន្ទាប់គ្នាចំនួនបី។ អនុកម្មវិធីបន្ទាប់និមួយៗនឹងត្រូវបានអនុវត្តជាបន្តបន្ទាប់ក្រោយការបញ្ចប់អនុកម្មវិធីមុន។ |
| ចំណាត់ថ្នាក់ | ចំណាត់ថ្នាក់គោលដៅ: អន្តរាគមន៍ទូទៅ<br>វិស័យ: ហិរញ្ញវត្ថុ<br>អនុវិស័យ: កិច្ចអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុ<br>ប្រធានបទ: កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និង អភិបាលកិច្ច<br>ប្រធានបទរង: ជំរុញប្រសិទ្ធភាពសេដ្ឋកិច្ចនិងទីផ្សារអំណោយផល និង អភិបាលកិច្ចខាងហិរញ្ញវត្ថុនិងសេដ្ឋកិច្ច។ |

| | |
|---|---|
| ការវាយតម្លៃបរិស្ថាន | ប្រភេទ C។ ផលប៉ះពាល់ខាងបរិស្ថានត្រូវបានពិនិត្យវាយតម្លៃ ហើយពុំឃើញមានផលប៉ះពាល់ជាអវិជ្ជមានធំដុំឡើយ។ |
| ការវាយតម្លៃវិស័យសង្គមកិច្ច | ការប្តូរទីលំនៅដោយមិនស្ម័គ្រចិត្ត: ប្រភេទ C<br>ផលប៉ះពាល់លើប្រជាជនអន្តោប្រាម: ប្រភេទ C<br>ពុំរំពឹងថាមានការប្តូរទីលំនៅដោយមិនស្ម័គ្រចិត្ត ឬ ផលប៉ះពាល់លើប្រជាជនអន្តោគ្រាម កើតចេញពីការអនុវត្តន៍កម្មវិធីនេះឡើយ។ |
| សនិទានភាពកម្មវិធី | វិស័យហិរញ្ញវត្ថុរបស់កម្ពុជា គឺស្ថិតនៅក្នុងតំណាក់កាលក្មេងខ្ចីដោយមានអន្តរការហិរញ្ញវត្ថុដ៏មានកិរិតនិងទំនុកចិត្តសាធារណ:ទាប។ ប្រព័ន្ធហិរញ្ញវត្ថុមិនទាន់លូតលាស់ គឺជាឧបសគ្គមួយនៃឧបសគ្គចំបងៗទាំងឡាយដែលរដ្ឋាភិបាលប្រឈម |

| | |
|---|---|
| | មុខ នៅក្នុងការសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពដែលមានមូលដ្ឋានធំទូលាយ និង គោលដៅអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ដែលរួមមានការកាត់បន្ថយភាពក្រីក្រ។ កិច្ចអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ត្រូវបានរារាំងដោយឧបសគ្គជាច្រើនៈ (១) ហានិភ័យខ្ពស់ពាក់ព័ន្ធនឹងភាពមិនប្រាកដប្រជានៃច្បាប់និងការយកកិច្ចសន្យាមកអនុវត្តដោយសារវិធានច្បាប់ទន់ខ្សោយ (២) ចំណាយដើម្បីទទួលបានព័ត៌មានតំលៃខ្ពស់ ដែលបណ្តាលមកពីកង្វះស្តង់ដារគណនេយ្យនិងសវនកម្មរួម និង ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានដទៃទៀត (៣) ចំណាយប្រតិបត្តិការខ្ពស់ ដោយសារមិនមានយន្តការគ្រប់គ្រងលើសាច់ប្រាក់ងាយស្រួលនិងហេដ្ឋារចនាសម្ព័ន្ធទីផ្សារដទៃទៀតនិង (៤) ប្រព័ន្ធត្រួតពិនិត្យនិងសមត្ថភាពនៅទន់ខ្សោយ។<br><br>FSPL គាំទ្រកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការដោះស្រាយឧបសគ្គទាំងនេះ និង រៀបចំមូលដ្ឋានសម្រាប់កិច្ចអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។ ប្រព័ន្ធហិរញ្ញវត្ថុរឹងមាំដែលមានប្រសិទ្ធភាព និង លក្ខណៈសមាហរណកម្ម គឺមានសារៈសំខាន់ក្រៃលែងដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ច ប្រកបដោយនិរន្តរភាពដែលមានមូលដ្ឋានធំទូលាយ និង ក្នុងការកាត់បន្ថយភាពក្រីក្រដោយបង្កើនកាលានុវត្តភាពការងារ កាត់បន្ថយចំណាយប្រតិបត្តិការនៃសកម្មភាពសេដ្ឋកិច្ច និង ការពង្រីកវិស័យហិរញ្ញវត្ថុត្រឹមត្រូវតាមផ្លូវការទៅដល់តំបន់ក្រីក្រនិងនៅជនបទ។ ប្រព័ន្ធហិរញ្ញវត្ថុដ៏មានប្រសិទ្ធភាពនឹងជំរុញកិច្ចអភិវឌ្ឍន៍វិស័យឯកជន ក៏ដូចជាវិនិយោគបរទេសផ្ទាល់ផងដែរ។ លើសពីនេះទៀត វិស័យហិរញ្ញវត្ថុមាំមួននឹងការពារសេដ្ឋកិច្ចទប់ទល់នឹងផលប៉ះពាល់មិនអំណោយផលពីខាងក្រៅដែលច្រើនកើតឡើងនៅក្នុងទីផ្សារហិរញ្ញវត្ថុដែលកាន់តែមានលក្ខណៈសកលភាវូបនីយកម្ម។ វឌ្ឍនភាពនៅក្រោមអនុកម្មវិធីទី ១ និង ២ បានឈានឱ្យមានការគាំទ្រដល់អនុកម្មវិធីទី ៣។ |
| គោលដៅ និង វិសាលភាព | FSPL សំដៅជំរុញកិច្ចអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុរឹងមាំនិងផ្អែកលើទីផ្សារមួយដើម្បីទ្រទ្រង់ការកៀងគរធនធាន និង កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពដោយបង្កើតមូលដ្ឋានសម្រាប់វិស័យធនាគារនិងធានារ៉ាប់រងក៏ដូចជាទីផ្សារហិរញ្ញវត្ថុ។ FSPL ផ្តោតលើសកម្មភាពដូចខាងក្រោមៈ |

| | |
|---|---|
| | (១) លើកកំពស់អន្តរការិយកម្មធនាគារនិងទំនុកចិត្តសាធារណៈ ដោយបង្កើតនិងពង្រឹងការត្រួតពិនិត្យធនាគារបង្កើតបណ្តាញសុវត្ថិភាពនិងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានសំខាន់ៗ កសាងសមត្ថភាពទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជនដោយឱ្យស្ថាប័នកសាងសមត្ថភាពជួយពង្រឹងគ្នាទៅវិញទៅមក។<br>(២) បង្កើតក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិសម្រាប់កិច្ចអភិវឌ្ឍន៍វិស័យធានារ៉ាប់រងដោយបង្កើតឱ្យទៅជាស្ថាប័ននូវប្រព័ន្ធត្រួតពិនិត្យនិងបទប្បញ្ញត្តិប្រុងប្រយ័ត្នជំរុញកិច្ចអភិវឌ្ឍន៍វិស័យឯកជននៅក្នុងអាជីវកម្មធានារ៉ាប់រង និង អភិវឌ្ឍការធានារ៉ាប់រងជាកាតព្វកិច្ច។<br>(៣) រៀបចំមូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍទីផ្សារអន្តរធនាគារនិងទីផ្សាររូបិយវត្ថុដោយកសាងភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជននិងដោយបង្កើតក្របខ័ណ្ឌច្បាប់ជាមូលដ្ឋាន។<br>(៤) អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ដោយបង្កើតស្តង់ដារគណនេយ្យរួមនិងយន្តការដាក់ឱ្យអនុវត្ត និង ដោយផ្សព្វផ្សាយច្បាប់ដើម្បីទ្រទ្រង់សកម្មភាពពាណិជ្ជកម្ម និង ទីផ្សារហិរញ្ញវត្ថុ។<br>យោលទៅលើវឌ្ឍនភាពសម្រេចបាននៅក្រោមអនុកម្មវិធីទី ១ និងទី ២ អនុកម្មវិធីទី ៣ នឹងរួមមានគំនិតផ្តួចផ្តើមគន្លឹះៗដូចខាងក្រោមនេះ:<br>(១) លើកកំពស់ហេដ្ឋារចនាសម្ព័ន្ធធនាគារ ដោយអនុម័តច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា បង្កើតប្រព័ន្ធចុះបញ្ជីសាធារណៈសម្រាប់ប្រតិបត្តិការដែលមានកិច្ចធានា និង បង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុដែលទទួលបន្ទុកលើការប្រឆាំងការលាងសំអាតប្រាក់ និង ប្រយុទ្ធនឹងហិរញ្ញប្បទានភេរវកម្ម។ ប្រការនេះនឹងជំរុញនិងរក្សាគោលការណ៍តម្លាភាព និង គណនេយ្យភាពតាមរយៈការសម្រេចបាននូវស្តង់ដារអន្តរជាតិដើម្បីកាត់បន្ថយហានិភ័យនៃការលាងសំអាតប្រាក់ ដោយអនុវត្តរបបតាមដាននិងអនុលោមភាពដ៏រឹងមាំមួយ។<br>(២) អនុម័តច្បាប់ពាណិជ្ជកម្មទាំងឡាយ និង កសាងសមត្ថភាពដោយ (ក) អនុម័តច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្ម (ខ)ដាក់ពង្រាងច្បាប់ស្តីពីធនក្ស័យ |

| | |
|---|---|
| | ជូនរដ្ឋសភាជាតិ (គ) ផ្សព្វផ្សាយច្បាប់ពាណិជ្ជកម្មតាមទំព័រអ៊ិនធឺណែត និងជួយរៀបចំកម្មវិធីសិក្សាច្បាប់ពាណិជ្ជកម្ម រួមមានការបណ្តុះបណ្តាលចៅក្រម មេធាវី និង បុគ្គលិកក្រឡាបញ្ជី អំពីច្បាប់ពាណិជ្ជកម្មថ្មីៗ ទាំងនេះ (ឃ) កែលំអក្របខ័ណ្ឌសម្រាប់អនុវិស័យធានារ៉ាប់រងដោយពង្រឹងការត្រួតពិនិត្យនិងបទប្បញ្ញត្តិប្រុងប្រយ័ត្ន តាមរយៈការអនុម័តនីតិវិធីចាំបាច់ទាំងឡាយ និង កសាងសមត្ថភាពទូទៅរបស់និយតករធានារ៉ាប់រង និង (ង) លើកកំពស់ការប្រកួតប្រជែងនៃទីផ្សារធានារ៉ាប់រងដោយធ្វើកំណែប្រែរចនាសម្ព័ន្ធក្រុមហ៊ុនធានារ៉ាប់រងរដ្ឋ និង វិនិយោគលក់ចេញឱ្យទៅវិស័យឯកជនកាន់កាប់ ។<br>(៣) រៀបចំមូលដ្ឋានគ្រឹះ សម្រាប់ទីផ្សារអន្តរធនាគារនិងទីផ្សាររូបិយវត្ថុដោយអនុម័តច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់និងយកវាមកអនុវត្តតាមរយៈនិយតកម្មសមស្រប និង ការបណ្តុះបណ្តាលបុគ្គលិក ។<br>(៤) អភិវឌ្ឍការអនុវត្តន៍គណនេយ្យនិងសវនកម្ម ដោយជួយសមាគមអ្នកជំនាញអាជីពនៅក្នុងការបណ្តុះបណ្តាលសមាជិក ឱ្យបានដល់កំរិតគុណវុឌ្ឍិតាមការកំណត់ទាំងឡាយ ។ |
| **ចំនួនឥណទាន និងល័ក្ខខ័ណ្ឌ** | ឥណទានចំនួន SDR៦.៧៦៣.000 (១០ លានដុល្លារ) នឹងត្រូវបានផ្តល់ចេញពីធនធានមូលនិធិពិសេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ ឥណទាននឹងមានកាលកំណត់ ២៤ ឆ្នាំ រួមទាំងរយៈពេលអនុគ្រោះ ៨ ឆ្នាំ និង អត្រាការប្រាក់ ១,0% ក្នុងមួយឆ្នាំ ក្នុងរយៈពេលអនុគ្រោះ និង ១,៥% ក្នុងមួយឆ្នាំក្រោយរយៈពេលអនុគ្រោះ ។ |
| **រយៈពេលនិងការកំណត់កញ្ចប់កម្មវិធី** | ឥណទាននេះនឹងត្រូវបានបើកផ្តល់ឱ្យតែក្នុងមួយកញ្ចប់ក្រោយការបំពេញល័ក្ខខ័ណ្ឌកញ្ចប់ជាក់លាក់ ។ អនុកម្មវិធីទី ៣ នឹងត្រូវបានអនុវត្តក្នុងរយៈពេល ១៨ ខែ ។ |
| **ស្ថាប័នប្រតិបត្តិ** | ធនាគារជាតិនៃកម្ពុជា នឹងបន្តធ្វើជាស្ថាប័នប្រតិបត្តិ ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្មគឺជាស្ថាប័នអនុវត្ត សម្រាប់អនុកម្មវិធីទី ៣ ។ ដើម្បីសម្របសម្រួលការអនុវត្តកម្មវិធីក្នុងចំណោមក្រសួងនិងស្ថាប័នរដ្ឋាភិបាល |

| | |
|---|---|
| | ពាក់ព័ន្ធ គណៈកម្មាធិការដឹកនាំវិស័យហិរញ្ញវត្ថុមួយត្រូវបានបង្កើតឡើង។ ក្រោមការដឹកនាំរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា គណៈកម្មាធិការនេះរួមមានមន្ត្រីជាន់ខ្ពស់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ធនាគារជាតិនៃកម្ពុជា និង ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធដទៃទៀត។ គណៈកម្មាធិការជួបប្រជុំប្រចាំត្រីមាសនិងតាមការងារជាក់ស្តែង ដើម្បីពិនិត្យមើលបញ្ហា និងលើកសំណើសកម្មភាពជាក់ស្តែងដើម្បីដោះស្រាយបញ្ហាទាំងនោះ ហើយដោយហេតុនេះធានាបាននូវការអនុវត្តន៍កម្មវិធីឱ្យបានទាន់ពេលវេលា។ មន្ត្រីជាន់ខ្ពស់មួយរូបរបស់ធនាគារជាតិនៃកម្ពុជា ដែលត្រូវបានតែងតាំងជានាយកកម្មវិធីនឹងបន្តជួយធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ក្នុងការសម្របសម្រួលការអនុវត្តន៍កម្មវិធីប្រចាំថ្ងៃ។ |
| លទ្ធកម្ម | ប្រាក់ពីឥណទាននឹងត្រូវបានប្រើដើម្បីធ្វើហិរញ្ញប្បទានលើចំណាយជារូបិយប័ណ្ណ (មិនរាប់បញ្ចូលពន្ធគយនិងពន្ធដារក្នុងស្រុកឡើយ) នៃរបស់ដែលត្រូវបានផលិតនិងធ្វើលទ្ធកម្មនៅក្នុងប្រទេសជាសមាជិកធនាគារអភិវឌ្ឍន៍អាស៊ី ដោយមិនរាប់បញ្ចូលរបស់ហាមឃាត់ និង ការនាំចូលដែលត្រូវបានធ្វើហិរញ្ញប្បទានដោយប្រភពឧភតោភាគីនិងពហុភាគីដទៃទៀត។ អនុលោមតាមបទប្បញ្ញត្តិនៃ *ការសម្រួលនៃនីតិវិធីបញ្ចេញប្រាក់និងល័ក្ខខ័ណ្ឌពាក់ព័ន្ធសម្រាប់ឥណទានជាកម្មវិធី* របស់ធនាគារអភិវឌ្ឍន៍អាស៊ី ប្រាក់ពីឥណទានកម្មវិធីនឹងត្រូវបានបើកជូនប្រទេសកម្ពុជាជាឥណវន្ត។ ពុំចាំបាច់មានឯកសារអមការនាំចូលទេប្រសិនបើក្នុងឆ្នាំនិមួយៗដែលប្រាក់ឥណទានទាំងនោះត្រូវបានរំពឹងថានឹងបើក ឃើញថាតម្លៃនៃការនាំចូលសរុបរបស់កម្ពុជាដកការនាំចូលពីប្រទេសមិនមែនជាសមាជិក ដកការនាំចូលហាមឃាត់ និង ការនាំចូលដែលត្រូវបានធ្វើហិរញ្ញប្បទានក្រោមជំនួយអភិវឌ្ឍន៍ផ្លូវការដទៃទៀត គឺស្មើនឹងឬច្រើនជាងចំនួននៃឥណទានដែលរំពឹងថានឹងត្រូវបានបើកនៅក្នុងឆ្នាំនោះ។ រដ្ឋាភិបាលនឹងចេញលិខិតបញ្ជាក់ការគោរពតាមរូបមន្តនេះរបស់ខ្លួន ដោយភ្ជាប់ជាមួយនឹងសំណើដកប្រាក់និមួយៗ។ បើពុំដូច្នោះទេ គេចាំបាច់តម្រូវឱ្យមានឯកសារនាំចូលក្រោមនីតិវិធីមានស្រាប់។ ធនាគារអភិវឌ្ឍន៍អាស៊ីរក្សាសិទ្ធិធ្វើសវនកម្មលើការប្រើប្រាក់ឥណទាន និង ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃលិខិតបញ្ជាក់របស់រដ្ឋាភិបាល។ |

| | |
|---|---|
| **មូលនិធិបដិភាគ** | ក្របខ័ណ្ឌគោលនយោបាយសម្រាប់កម្មវិធីនេះ រួមមានផ្នែកជាក់លាក់ដែលកំណត់ចំណាយដោយឡែកនៃកំណែទម្រង់លើវចនាសម្ព័ន្ធ។ មូលនិធិបដិភាគដែលនឹងត្រូវបានមកពីប្រាក់ឥណទាន នឹងត្រូវបានប្រើដើម្បីធ្វើហិរញ្ញប្បទានដល់ចំណាយនៃកំណែទម្រង់លើវចនាសម្ព័ន្ធដែលត្រូវធ្វើឡើងក្នុង FSPL ។ |
| **ហានិភ័យ និង ការការពារ** | ហានិភ័យគោលដែលពាក់ព័ន្ធនឹងអនុកម្មវិធីទី ៣ ទាក់ទិននឹងចំនួនច្បាប់ដែលតម្រូវឱ្យមានការអនុម័តដោយរដ្ឋសភាជាតិ។ ច្បាប់ទាំងនេះទទួលការគាំទ្រដ៏សកម្មពីក្រសួងពាក់ព័ន្ធទាំងឡាយ និង ធនាគារជាតិនៃកម្ពុជា។ ស្ថាប័នទាំងនេះបានខិតខំពន្យល់អ្នកធ្វើច្បាប់ទាំងឡាយនៅក្នុងគណៈកម្មការពាក់ព័ន្ធ ដើម្បីឱ្យគណៈកម្មាធិការទាំងនេះបានយល់អំពីតួនាទីដ៏សំខាន់របស់ច្បាប់និមួយៗ។ បន្ថែមលើការគាំទ្រដ៏រឹងមាំនៃស្ថាប័នធានារបស់រដ្ឋាភិបាល ច្បាប់ភាគច្រើនគឺស្ថិតនៅក្នុងតំណាក់កាលដ៏ជឿនលឿននៃការពិចារណាដោយរដ្ឋសភាជាតិ។ ក្នុង ខែ មិថុនា ឆ្នាំ ២០០៥ វិសោធនកម្មមួយលើរដ្ឋធម្មនុញ្ញ ដោយបានបន្ថយចំនួនកំណត់នៃសមាជិកសភាដែលចាំបាច់សម្រាប់បង្កើតជាកូរ៉ុមសម្រាប់គោលបំណងអនុម័ត ច្បាប់ ពី ៨៧ មក ៧៤ នាក់។ ប្រការនេះគួរនឹងជួយបង្កើនល្បឿននៃការអនុម័តច្បាប់បាន។<br><br>ការបង្កើតស្ថាប័នទាំងឡាយដូចជា អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា និង ការបង្កើនសមត្ថភាពនិយតករធានារ៉ាប់រង គឺអាស្រ័យលើការមានមូលនិធិ និង ការប្រឹងប្រែងរបស់មន្ត្រីនិងស្ថាប័នពាក់ព័ន្ធ។ កិច្ចអភិវឌ្ឍន៍ស្ថាប័នទាំងនេះភាគច្រើននឹងត្រូវបានជួយទ្រទ្រង់តាមរយៈការបែងចែកថវិកាយ៉ាងហោចណាស់ក៏មួយចំណែកពីមូលនិធិបដិភាគក្រោមកម្មវិធីនេះ។ បន្ថែមលើនេះទៀត សកម្មភាពទាំងនេះនឹងត្រូវបានគាំទ្រតាមរយៈជំនួយបច្ចេកទេសដែលភ្ជាប់ជាមួយនឹងអនុកម្មវិធីទី ៣ ឬ ពីដៃគូអភិវឌ្ឍន៍ដទៃទៀត។ សំណើទាំងអស់នេះទទួលបានការគាំទ្រយ៉ាងមាំទាំពីស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ និង ពុំមែនពឹងផ្អែកទាំងស្រុងតែលើការគាំទ្រពីមន្ត្រីជាបុគ្គលទាំងឡាយឡើយ។<br><br>លទ្ធផលអនុវត្តន៍ដែលសម្រេចបានក្រោមអនុកម្មវិធីទី ១ និងទី ២ បង្ហាញជំនឿថាហានិភ័យទាំងនេះមានលក្ខណៈអាចគ្រប់គ្រងបាន ។ |

| | |
|---|---|
| **ជំនួយបច្ចេកទេស** | ធនាគារអភិវឌ្ឍន៍អាស៊ីនឹងផ្តល់ជំនួយបច្ចេកទេស (០,៥ លានដុល្លារ) ដើម្បីជួយឧបត្ថម្ភធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ក្នុងការអនុវត្តន៍គោលនយោបាយនិងកំណែទម្រង់ស្ថាប័នផ្សេងៗក្រោម អនុកម្មវិធីទី៣។ សកម្មភាពជំនួយបច្ចេកទេសសំខាន់ៗ រួមមានៈ (១) ការគាំទ្រដល់ធនាគារជាតិនៃកម្ពុជា ក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនដើម្បីកែលំអការត្រួតពិនិត្យនៅនឹងកន្លែងរបស់ខ្លួន និង ការត្រួតពិនិត្យធនាគារ (២) ការគាំទ្រខាងបច្ចេកទេសដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជួយក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួងដើម្បីពង្រឹងសមត្ថភាពនៃនិយតករធានារ៉ាប់រង និង កំណែទម្រង់ក្រុមហ៊ុនធានារ៉ាប់រងរដ្ឋ (កាមីនកូ) និង (៣) ការគាំទ្រខាងបច្ចេកទេសដល់ក្រសួងពាណិជ្ជកម្មក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនដើម្បីអនុវត្តច្បាប់ពាណិជ្ជកម្ម ផ្សេងៗ និង បទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយ។ |

## ម៉ាទ្រីសគោលនយោបាយសម្រាប់អនុកម្មវិធីទី ៣

| គោលដៅ | ល័ក្ខខ័ណ្ឌ | កាលបរិច្ឆេទគ្រោងបញ្ចប់ |
|---|---|---|
| **កិច្ចអភិវឌ្ឍន៍អនុវិស័យធនាគារ** | | |
| ក. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអនុវិស័យធនាគារ | រដ្ឋសភាជាតិអនុម័តច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ | ខែ កញ្ញា ឆ្នាំ ២០០៦ |
| | ក្រសួងពាណិជ្ជកម្មបង្កើតប្រព័ន្ធចុះបញ្ជីសាធារណៈសម្រាប់ប្រតិបត្តិការដែលមានកិច្ចធានា។ | ខែ មិនា ឆ្នាំ ២០០៦ |
| | ធនាគារជាតិនៃកម្ពុជាបង្កើតអង្គភាពមួយ និង ធ្វើការងារត្រៀមដែលចាំបាច់សម្រាប់ការបង្កើតអង្គភាពស៊ើបការណសម្ងាត់ហិរញ្ញវត្ថុដែលទទួលបន្ទុកលើការប្រឆាំងការលាងសំអាតប្រាក់ និងការប្រយុទ្ធនឹងហិរញ្ញប្បទានភេរវកម្ម។ * | ខែ មិថុនា ឆ្នាំ ២០០៦ |
| ខ. អភិវឌ្ឍច្បាប់ពាណិជ្ជកម្ម និង កសាងសមត្ថភាព | រដ្ឋសភាជាតិអនុម័តច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្ម។ * | ខែ មិនា ឆ្នាំ ២០០៦ |
| | ក្រសួងពាណិជ្ជកម្មដាក់ច្បាប់ស្តីពីធនក្ស័យជូនរដ្ឋសភាជាតិ។ | ខែ មេសា ឆ្នាំ ២០០៦ |
| | ក្រសួងពាណិជ្ជកម្មធានាឱ្យបាននូវការផ្សព្វផ្សាយច្បាប់ពាណិជ្ជកម្មទាំងឡាយតាមអ៊ិនធឺណែត។ * | ខែ ធ្នូ ឆ្នាំ ២០០៥ |
| | ក្រសួងពាណិជ្ជកម្មធ្វើការងារជាមួយស្ថាប័នច្បាប់ពាក់ព័ន្ធ ដើម្បីរៀបចំនិងអនុម័តកម្មវិធីសិក្សាច្បាប់ដែលផ្អែកលើច្បាប់ពាណិជ្ជកម្មថ្មីៗទាំងឡាយ សម្រាប់បណ្តុះបណ្តាលចៅក្រម អ្នកច្បាប់ និង | ខែ មិនា ឆ្នាំ ២០០៦ |

| គោលដៅ | ល័ក្ខខ័ណ្ឌ | កាលបរិច្ឆេទគ្រោងបញ្ចប់ |
|---|---|---|
| | បុគ្គលិកក្រឡាបញ្ជី ។ * | |
| **កិច្ចអភិវឌ្ឍន៍វិស័យធានារ៉ាប់រង** | | |
| គ. ពង្រឹងសមត្ថភាពរបស់និយតករ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យឡើងវិញ កែសម្រួលជាថ្មី និង អនុវត្តបទប្បញ្ញត្តិប្រុងប្រយ័ត្ន សមស្របទាំងឡាយដើម្បីលើកកំពស់សាធនភាព សាច់ប្រាក់ងាយស្រួល និង ល័ក្ខខ័ណ្ឌអភិបាល-កិច្ចសាជីវកម្មល្អ និង ផ្តល់ការគាំទ្របច្ចេកទេសដល់និយតករធានារ៉ាប់រង ។ * | ខែ មិថុនា ឆ្នាំ ២០០៦ |
| ឃ. ជំរុញការចូលរួមរបស់វិស័យឯកជននៅក្នុងវិស័យធានារ៉ាប់រង | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងអនុវត្តសកម្មភាពគន្លឹះនៃផែនការដើម្បីធ្វើកំណែទម្រង់កាមីនកូ ដូចបានឯកភាពជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងន័យដើម្បីវិនិយោគលក់ចេញនូវភាគហ៊ុនរបស់រដ្ឋឱ្យបានយ៉ាងឆាប់បំផុត ។ | ខែ សីហា ឆ្នាំ ២០០៦ |
| **កិច្ចអភិវឌ្ឍន៍ទីផ្សារអន្តរធនាគារ និង ទីផ្សាររូបិយវត្ថុ** | | |
| ង. អភិវឌ្ឍក្របខ័ណ្ឌច្បាប់សម្រាប់ទីផ្សាររូបិយវត្ថុ | រដ្ឋសភាជាតិអនុម័តច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់ ។<br>ធនាគារជាតិធ្វើសេចក្តីព្រាងនិងអនុម័តបទប្បញ្ញត្តិសម្រាប់អនុវត្តច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់ ។ * | ខែ មិថុនា ឆ្នាំ ២០០៦<br>ខែ កញ្ញា ឆ្នាំ ២០០៦ |

| គោលដៅ | លទ្ធផល | កាលបរិច្ឆេទគ្រោងបញ្ចប់ |
| --- | --- | --- |
| **កិច្ចអភិវឌ្ឍន៍ការអនុវត្តគណនេយ្យ និង សវនកម្ម** | | |
| ច. ផ្ដល់ការគាំទ្រខាងសមត្ថភាពដើម្បីអភិវឌ្ឍសមាជិកអាជីពនៃវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (KICPAA) | ក្រសួងហិរញ្ញវត្ថុធានាឱ្យបាននូវការគាំទ្រខាងហិរញ្ញវត្ថុសម្រាប់អាហារូបករណ៍យ៉ាងតិចបំផុត ចំនួន ៧០ ក្នុងមួយឆ្នាំ ដើម្បីកិច្ចអភិវឌ្ឍន៍សមាជិកអាជីពនៃវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (KICPAA) ។* | ខែ មេសា ឆ្នាំ ២០០៦ |

* លទ្ធផលថ្មីដែលបានស្នើឡើង

# ជំនួយបច្ចេកទេស

## ក. គោលបំណង និង សមិទ្ធផល

១. គោលបំណងចំបងនៃជំនួយបច្ចេកទេស គឺដើម្បីជួយរដ្ឋាភិបាលក្នុងការកែលំអសមត្ថភាពនៃធនាគារជាតិនៃកម្ពុជា ដែលជាស្ថាប័នប្រតិបត្តិ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ដែលគឺជាស្ថាប័នអនុវត្ត ដើម្បីអនុវត្តសកម្មភាពគោលនយោបាយក្រោមអនុកម្មវិធីទី៣នៃឥណទានកម្មវិធីវិស័យហិរញ្ញវត្ថុ (FSPL)។ ប្រការនេះតម្រូវឱ្យមានការផ្តល់ជំនាញបច្ចេកទេស និង ការជួយបង្ហាត់បង្រៀនការងារនៅនឹងកន្លែងឱ្យបានចំតាមគោលដៅ ដើម្បីបំពាក់ឱ្យស្ថាប័នរដ្ឋាភិបាលសំខាន់ៗទាំងឡាយដូចជាធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ដើម្បីផ្តល់ចំណេះដឹងនិងជំនាញសមស្របដើម្បីបន្តកំណែទម្រង់ចាំបាច់ទាំងឡាយ ដែលត្រូវបានផ្តួចផ្តើមឡើងក្រោមអនុកម្មវិធីទី ១ និង ទី២ លើមូលដ្ឋានប្រកបដោយនិរន្តរភាព។

២. បន្តពីសមិទ្ធផលដែលទទួលបានក្រោមអនុកម្មវិធីទី ១ និង ទី២ ជំនួយបច្ចេកទេសនេះនឹងផ្តោតលើការសម្រេចឱ្យបាននូវសមិទ្ធផលផលចំបងៗចំនួនបី នៅក្នុងការគាំទ្រគំនិតផ្តួចផ្តើមគោលនយោបាយរបស់អនុកម្មវិធីទី ៣:

(i) **ពង្រឹងការត្រួតពិនិត្យធនាគារនិងប្រព័ន្ធទូទាត់**

ពង្រឹងសមត្ថភាពត្រួតពិនិត្យនៅនឹងកន្លែងរបស់និយតករធនាគារ គាំទ្រការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុនៅក្នុងធនាគារជាតិនៃកម្ពុជា ដើម្បីលើកកំពស់ការត្រួតពិនិត្យធនាគារ និង ទំនុកចិត្តសាធារណៈ និង លើកកំពស់ការយល់ដឹងនិងការទទួលយកសាធារណៈនូវច្បាប់ថ្មីស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់។

(ii) **អភិវឌ្ឍវិស័យធានារ៉ាប់រង**

កែលំអបទប្បញ្ញត្តិប្រុងប្រយ័ត្នវិស័យធានារ៉ាប់រង និង ពង្រឹងសមត្ថភាពរបស់និយតករវិស័យធានារ៉ាប់រងនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ) ដើម្បីអនុវត្តបទប្បញ្ញត្តិទាំងនេះ និង ជួយដល់ការអនុវត្តផែនការកែទម្រង់ក្រុមហ៊ុនធានារ៉ាប់រងរដ្ឋ (កាមីនកូ)។

(iii) **អភិវឌ្ឍច្បាប់ពាណិជ្ជកម្មនិងកសាងសមត្ថភាព**

ផ្តល់ការគាំទ្រជាការបណ្តុះបណ្តាល ដើម្បីលើកកំពស់ការយល់ដឹង និង ការអនុវត្តច្បាប់ពាណិជ្ជកម្មថ្មីៗរបស់ចៅក្រម មេធាវី និង ក្រឡាបញ្ជីដែលទទួលបន្ទុកពាណិជ្ជកិច្ច។

## ៩. វិធីសាស្ត្រ និង សកម្មភាពសំខាន់ៗ

៣. អ្នកពិគ្រោះការងារជំនួយបច្ចេកទេសទាំងឡាយ នឹងផ្តល់នូវជំនាញឯកទេសដាច់ដោយឡែកពីគ្នានៅក្នុងវិស័យដូចតទៅនេះ: (១) ការត្រួតពិនិត្យធនាគារនិងការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ (២) លើកកំពស់ការយល់ដឹងពីរបបឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់ (៣) ការត្រួតពិនិត្យសកម្មភាពធានារ៉ាប់រង និង ការបណ្តុះបណ្តាលដែលពាក់ព័ន្ធ (៤) កំណែទម្រង់ក្រុមហ៊ុនធានារ៉ាប់រងរដ្ឋ (កាមីនកូ) និង (៥) ផ្តល់ការបណ្តុះបណ្តាលស្តីពីច្បាប់ពាណិជ្ជកម្ម។ អ្នកឯកទេសត្រួតពិនិត្យធនាគារនឹងជួយ (១) រៀបចំនីតិវិធីត្រួតពិនិត្យនៅនឹងកន្លែង និង ធ្វើការបណ្តុះបណ្តាលផ្ទាល់នៅនឹងកន្លែងដល់បុគ្គលិកអំពីការអនុវត្តនីតិវិធីទាំងនោះ និង (២) បង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ។ អ្នកឯកទេសច្បាប់ខាងប្រព័ន្ធឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់ នឹងធ្វើការផ្សព្វផ្សាយសាធារណៈនូវច្បាប់ថ្មីនេះ និង បទប្បញ្ញត្តិសំរាប់អនុវត្តច្បាប់នេះ។ អ្នកឯកទេសខាងត្រួតពិនិត្យវិស័យធានារ៉ាប់រងនឹងរៀបចំដំណើរទស្សនកិច្ចសិក្សាមួយ សម្រួលជាថ្មីនូវក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់វិស័យធានារ៉ាប់រង និង ផ្តល់ការបណ្តុះបណ្តាលផ្ទាល់នៅនឹងកន្លែងការងារដល់បុគ្គលិក នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អំពីការអនុវត្តបទប្បញ្ញត្តិទាំងនោះ បែបបទឯកសារ សកម្មភាពតាមដាននិង/ឬ សកម្មភាពកែតម្រូវ។ អ្នកឯកទេសខាងកំណែទម្រង់សាជីវកម្មធានារ៉ាប់រង នឹងជួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង កាមីនកូក្នុងការអនុវត្តន៍ផែនការកំណែទម្រង់ក្រុមហ៊ុនកាមីនកូ។ អ្នកឯកទេសខាងច្បាប់ពាណិជ្ជកម្មនឹងត្រូវរៀបចំកម្មវិធីសិក្សាច្បាប់ពាណិជ្ជកម្ម និង មេរៀនបណ្តុះបណ្តាល ដែលនឹងត្រូវបានប្រើដោយមហាវិទ្យាល័យច្បាប់ ផ្សេងៗនៅប្រទេសកម្ពុជា និង រៀបចំសិក្ខាសាលាស្តីពីប្រធានបទនេះសម្រាប់សាស្ត្រាចារ្យនៅតាមមហាវិទ្យាល័យច្បាប់ ចៅក្រម មេធាវី និង បុគ្គលិកបម្រើការនៅតុលាការ ដោយមានអនុសាសន៍សម្រាប់ធានាឱ្យបាននូវការបន្តកម្មវិធីបណ្តុះបណ្តាល។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងតាមដានយ៉ាងយកចិត្តទុកដាក់នូវសកម្មភាពទាំងឡាយនៅក្នុងផ្នែកនិមួយៗនៃកម្មវិធី ដើម្បីធានាឱ្យបាននូវគុណភាពនៃផលដែលសំរេចបាន និង សមិទ្ធផលទាំងឡាយ ក្រោមធនធានថវិកាដែលបានអនុម័តរួច។

## គ. ចំណាយ និង ហិរញ្ញប្បទាន

៤. ជំនួយបច្ចេកទេសនេះត្រូវបានប៉ាន់ស្មានថាមានចំណាយសរុបស្មើនឹងចំនួន ៦៥០.០០០ ដុល្លារ ដែលរួមមានចំណាយរូបិយប័ណ្ណ ៤៣៥.០០០ ដុល្លារ និង ចំណាយរូបិយវត្ថុក្នុងស្រុកស្មើនឹងចំនួន ២១៥.០០០ ដុល្លារ។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងផ្តល់ប្រាក់ចំនួន ៥០០.០០០ ដុល្លារ ជាជំនួយឥតសំណង ពីកម្មវិធីផ្តល់មូលនិធិជំនួយបច្ចេកទេសរបស់ខ្លួន ដើម្បីផ្តល់ហិរញ្ញប្បទានលើចំណាយរូបិយប័ណ្ណទាំងមូល បូកនឹង ចំណាយរូបិយវត្ថុក្នុងស្រុកដែលមានតំលៃស្មើនឹង ៦៥.០០០ ដុល្លារ។ រាជរដ្ឋាភិបាលនឹងផ្តល់ហិរញ្ញប្បទានលើចំនួននៅសល់សំរាប់ចំណាយរូបិយវត្ថុក្នុងស្រុកដែលមានតំលៃស្មើនឹង ១៥០.០០០ ដុល្លារ ដែលរួមមានការផ្តល់បុគ្គលិកដៃគូ ការិយាល័យ ជំនួយខាងរដ្ឋបាល និង សេវាផ្សេងៗដទៃទៀត។ ការប៉ាន់ស្មានចំណាយ និង ផែនការហិរញ្ញប្បទានគឺមាននៅក្នុង តារាង ក៥។

**តារាង ក៥: ការប៉ាន់ស្មានចំណាយ និង ផែនការហិរញ្ញប្បទាន**

**($)**

| មុខចំណាយ | រូបិយប័ណ្ណ | រូបិយវត្ថុក្នុងស្រុក | ចំណាយសរុប |
|---|---|---|---|
| **ក. ហិរញ្ញប្បទានធនាគារអភិវឌ្ឍន៍អាស៊ី** | | | |
| ១. អ្នកពិគ្រោះការងារ | | | |
| ក. ប្រាក់ឈ្នួល និង សោហ៊ុយប្រចាំថ្ងៃ | | | |
| i. អ្នកពិគ្រោះការងារអន្តរជាតិ | ៣០៧.៥០០ | ០ | ៣០៧.៥០០ |
| ii. អ្នកពិគ្រោះការងារក្នុងស្រុក | ០ | ៤០.០០០ | ៤០.០០០ |
| ខ. ការធ្វើដំណើរអន្តរជាតិនិងក្នុងស្រុក | ៦៥.០០០ | ៥.០០០ | ៧០.០០០ |
| គ. របាយការណ៍និងការប្រាស្រ័យទាក់ទង | ៥.០០០ | ០ | ៥.០០០ |
| ២. បណ្តុះបណ្តាល សិក្ខាសាលា និង ប្រជុំ | | | |
| ក. ទស្សនកិច្ចសិក្សា | ១០.០០០ | ០ | ១០.០០០ |
| ខ. សិក្ខាសាលា | ០ | ១៧.០០០ | ១៧.០០០ |
| ៣. ថវិកាបម្រុង | ៤៧.៥០០ | ៣.០០០ | ៥០.៥០០ |
| សរុប (ក) | ៤៣៥.០០០ | ៦៥.០០០ | ៥០០.០០០ |
| **ខ. ហិរញ្ញប្បទានរាជរដ្ឋាភិបាល** | | | |
| ១. ការិយាល័យ និង សេវាកម្ម លេខាធិការដ្ឋាន | ០ | ៤៥.០០០ | ៤៥.០០០ |
| ២. ប្រាក់ឈ្នួល និង សោហ៊ុយប្រចាំថ្ងៃ | ០ | ៥០.០០០ | ៥០.០០០ |

| | | | |
|---|---|---|---|
| របស់បុគ្គលិកដៃគូ | | | |
| ៣. បរិក្ខារូបវ័ន្តសម្រាប់សិក្ខាសាលា | 0 | ៣0.000 | ៣0.000 |
| ៣. ផ្សេងៗ | 0 | ២៥.000 | ២៥.000 |
| សរុប (ខ) | 0 | ១៥0.000 | ១៥0.000 |
| **សរុបរួម** | ៤៣៥.000 | ២១៥.000 | ៦៥0.000 |

[ក] ផ្តល់ហិរញ្ញប្បទានដោយកម្មវិធីផ្តល់មូលនិធិជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

ប្រភព: ការប៉ាន់ស្មានធនាគារអភិវឌ្ឍន៍អាស៊ី

## ឃ. កិច្ចព្រមព្រៀងអនុវត្តន៍

៥. ធនាគារជាតិនៃកម្ពុជា នឹងទទួលខុសត្រូវលើការត្រួតពិនិត្យធនាគារនិងការផ្សព្វផ្សាយជាសាធារណៈ លើផ្នែករបបឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់ និង សម្របសម្រួលសកម្មភាពជំនួយបច្ចេកទេសតាមរយៈគណៈកម្មាធិការដឹកនាំវិស័យហិរញ្ញវត្ថុ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺជាស្ថាប័នអនុវត្តសម្រាប់ផ្នែកវិស័យធានារ៉ាប់រង ហើយក្រសួងពាណិជ្ជកម្មគឺជាស្ថាប័នអនុវត្តសម្រាប់ការបណ្តុះបណ្តាលលើផ្នែកច្បាប់ពាណិជ្ជកម្ម។ ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្មនឹងផ្តល់ការិយាល័យ បុគ្គលិកដៃគូ និង សេវាកម្មគាំទ្រដទៃទៀតជូនដល់អ្នកពិគ្រោះការងារ។

៦. ធនាគារអភិវឌ្ឍន៍អាស៊ីនឹងជួលអ្នកពិគ្រោះការងារដោយឡែកៗឱ្យផ្តល់សេវាកម្មពិគ្រោះការងារគិតគ្នាជាសរុបចំនួន ២៩.៥ ខែ។ ចំនួននេះនឹងរួមមាន ១៥.៥ ខែសំរាប់អ្នកពិគ្រោះការងារអន្តរជាតិ និង ១៤ ខែសំរាប់អ្នកពិគ្រោះការងារក្នុងស្រុក។ អ្នកពិគ្រោះការងារនឹងត្រូវជួលដោយធនាគារអភិវឌ្ឍន៍អាស៊ីលើមូលដ្ឋានឯកត្តបុគ្គល (អ្នកពិគ្រោះការងារពីវិស័យជំនាញពាក់ព័ន្ធនឹងត្រូវបានជ្រើសរើសតាមរយៈក្រុមហ៊ុន) ដោយអនុលោមតាម *សេចក្តីណែនាំស្តីពីការប្រើអ្នកពិគ្រោះការងារដោយធនាគារអភិវឌ្ឍន៍អាស៊ីនិងភ្នាក់ងាររបស់ខ្លួន* និង តាមកិច្ចព្រមព្រៀងដទៃទៀតដែលគួរជាទីពេញចិត្តចំពោះធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់ការជួលអ្នកពិគ្រោះការងារក្នុងស្រុក។

៧. អ្នកពិគ្រោះការងារនឹងផ្តល់របាយការណ៍ចាប់ផ្តើមដំបូង របាយការណ៍បណ្តោះអាសន្ន និង ពង្រាងចុងក្រោយសម្រាប់ផ្នែកនិមួយៗ។ របាយការណ៍ចាប់ផ្តើមដំបូងនឹងត្រូវបានប្រគល់ក្នុងរយៈពេល ៣ សប្តាហ៍ចាប់ពីពេលចាប់ផ្តើមការងារ នឹងរួមមានផែនការការងារនិងលទ្ធផលដែលមានកំណត់ពេលវេលា។ របាយការណ៍បណ្តោះអាសន្ននឹងត្រូវបានប្រគល់នៅពេលបញ្ចប់កិច្ចសន្យាបានពាក់កណ្តាល ហើយ

ពង្រាងរបាយការណ៍ចុងក្រោយ ត្រូវបានប្រគល់យ៉ាងហោចណាស់ ៣ សប្តាហ៍ មុនពេលបញ្ចប់កិច្ចសន្យា។ របាយការណ៍ចុងក្រោយដែលត្រូវឆ្លុះបញ្ចាំងនូវមតិយោបល់ពីស្ថាប័នអនុវត្ត និង ធនាគារអភិវឌ្ឍន៍អាស៊ី គប្បីត្រូវបានប្រគល់នៅពេលបញ្ចប់សេវារបស់ខ្លួន។ ជំនួយបច្ចេកទេសត្រូវបានគ្រោងនឹងចាប់ផ្តើមនៅមុនថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ និង ត្រូវបញ្ចប់មុនថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ២០០៧។

## ៦. ភារកិច្ចរបស់អ្នកពិគ្រោះការងារ

### ១. អ្នកពិគ្រោះការងារអន្តរជាតិ

#### ក. អ្នកឯកទេសខាងត្រួតពិនិត្យធនាគារ[១] (៤ ខែ មានចន្លោះពេល)

៨. អ្នកឯកទេសត្រួតពិនិត្យធនាគារ ត្រូវមានបទពិសោធន៍ការងារច្រើននៅក្នុងផ្នែកផ្សេងៗនៃការត្រួតពិនិត្យធនាគារ រួមមានការត្រួតពិនិត្យនៅនឹងកន្លែង និង ត្រូវយល់ដឹងពីស្តង់ដារអន្តរជាតិ និង ការអនុវត្តន៍ប្រសើរបំផុត។ ការយល់ដឹងពីក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិមានស្រាប់នៃប្រព័ន្ធធនាគារកម្ពុជាគឺជាគុណសម្បត្តិមួយ។ អ្នកឯកទេសនឹងជួយនាយកដ្ឋានត្រួតពិនិត្យរបស់ធនាគារនៃកម្ពុជាតាមរយៈការចុះធ្វើទស្សនៈកិច្ចការងារចំនួនបី ដោយលើកកំពស់សមត្ថភាពត្រួតពិនិត្យនៅនឹងកន្លែងរបស់បុគ្គលិកនៃនាយកដ្ឋាន។ លើសពីនេះទៀត អ្នកឯកទេសនឹងបំពេញភារកិច្ចដូចខាងក្រោមនេះ:

(i) ពិនិត្យឡើងវិញនូវបទប្បញ្ញត្តិប្រុងប្រយ័ត្ន និង ឯកសារត្រួតពិនិត្យនៅនឹងកន្លែង។ ពិភាក្សាជាមួយបុគ្គលិកដើម្បីកំណត់ចន្លោះប្រហោងនៅក្នុងបទប្បញ្ញត្តិ និងការអនុវត្តន៍បទប្បញ្ញត្តិទាំងនេះ និង តម្រូវការខាងការបណ្តុះបណ្តាលរបស់បុគ្គលិកត្រួតពិនិត្យនៅនឹងកន្លែង ។

(ii) លើកជាសំណើកែប្រែដើម្បីកែលំអបទប្បញ្ញត្តិប្រុងប្រយ័ត្ន។ សំណើកែប្រែ ត្រូវតែយល់ដឹងអំពីបរិយាកាសធនាគារនៅក្នុងប្រទេសកម្ពុជានិងតំបន់ ទាក់ទិនទៅនឹងប្រភេទផ្សេងៗនៃធុរកិច្ច ផលិតផលសេវា និង ការអនុវត្តន៍។

(iii) ពិគ្រោះយោបល់ជាមួយអ្នករួមចំណែកដែលពាក់ព័ន្ធ និង រៀបចំនីតិវិធីត្រួតពិនិត្យ

[១] ធនាគារជាតិនៃកម្ពុជាបានស្នើសុំឱ្យប្រើចំណែកថវិកាសម្រាប់អ្នកពិគ្រោះការងារក្នុងស្រុកសម្រាប់សិក្ខាសាលាយល់ដឹង ដើម្បីផ្សព្វផ្សាយច្បាប់ថ្មីស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់ រួមមានការអនុវត្តបទប្បញ្ញត្តិច្បាប់នេះផង។ បុគ្គលិកនៃនាយកដ្ឋានត្រួតពិនិត្យធនាគារ នឹងផ្តល់ការគាំទ្រចាំបាច់ទាំងអស់ជូនដល់អ្នកឯកទេសអន្តរជាតិ។ ក្រុមបេសកកម្មបានគាំទ្រសំណើនេះ ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងតារាងនៃការប៉ាន់ស្មានចំណាយ និង ផែនការហិរញ្ញប្បទាន។

នៅនឹងកន្លែងដែលផ្អែកតាមហានិភ័យ ដែលសមស្របនឹងបរិយាកាសធនាគារនៅក្នុងប្រទេសកម្ពុជានិងតំបន់ ទាក់ទិនទៅនឹងប្រភេទ ផ្សេងៗនៃធុរកិច្ច ផលិតផលសេវា និងការអនុវត្តន៍។

(iv) ពិគ្រោះយោបល់ជាមួយអ្នករួមចំណែកដែលពាក់ព័ន្ធ ដើម្បីរៀបចំកម្មវិធីការងារសំរាប់ការចុះនៅនឹងកន្លែង ដែលនឹងផ្តល់លទ្ធភាពឱ្យបុគ្គលិកអង្គភាពអាចធ្វើអធិការកិច្ចនៅនឹងកន្លែងលើធនាគារទាំងអស់បាន។ គេគប្បីផ្តោតការយកចិត្តទុកដាក់ឱ្យបានខ្លាំងលើធនាគារទាំងឡាយណាដែលបង្ហាញ ហានិភ័យចាប់ពីមធ្យមដល់ខ្ពស់នៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

(v) ផ្តល់ការណែនាំនៅកន្លែងការងារជូនដល់បុគ្គលិកអំពីការអនុវត្តន៍នីតិវិធីទាំងនោះចំពោះធនាគារយ៉ាងតិចចំនួន ៣ (ធនាគារពីរត្រូវស្ថិតនៅក្នុងប្រភេទ "ហានិភ័យខ្ពស់")។ ធានាឱ្យបានប្រាកដថា បុគ្គលិកបានទទួលការបណ្តុះបណ្តាលខ្លះអំពីការរៀបចំផែនការចុះអធិការកិច្ចនៅនឹងកន្លែង អាចរៀបចំឯកសារ ធ្វើការវិភាគ វាយតម្លៃ និងរាយការណ៍របកគំហើញរបស់ខ្លួន ផ្តល់អនុសាសន៍សម្រាប់សកម្មភាពបន្ត និងអនុវត្តសកម្មភាពទាំងនោះ។

(vi) ជួយនាយកដ្ឋានត្រួតពិនិត្យក្នុងការកំណត់ភារកិច្ចការងារនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ កំណត់តម្រូវការបុគ្គលិក និង ការបង្កើតអង្គភាពនេះ។

(vii) ផ្តល់របាយការណ៍ចាប់ផ្តើមដំបូង របាយការណ៍បណ្តោះអាសន្ន និង ចុងក្រោយតាមដែលបានកំណត់ ជូនដល់ធនាគារជាតិនៃកម្ពុជា និង ធនាគារអភិវឌ្ឍន៍អាស៊ី។

**ខ. អ្នកឯកទេសច្បាប់ខាងឧបករណ៍អាចជួញដូរបាននិងប្រព័ន្ធទូទាត់ (២ ខែ មានចន្លោះពេល)**

៩. អ្នកឯកទេសនេះត្រូវតែមានចំណេះដឹងខាងច្បាប់លើប្រព័ន្ធទូទាត់និង/ឬផាត់ទាត់ ដោយមានបទពិសោធន៍ការងារច្រើនក្នុងការរៀបចំឯកសារសម្រាប់សិក្ខាសាលា និងធ្វើសិក្ខាសាលាដើម្បីពន្យល់អំពីរបបនេះ ជូនដល់អ្នកពាក់ព័ន្ធដែលមានចំណេះដឹងស្តួចស្តើងអំពីប្រធានបទនេះ។ ការយល់ដឹងពីក្របខ័ណ្ឌច្បាប់ និង បទប្បញ្ញត្តិសម្រាប់ការងារធនាគារ ហិរញ្ញវត្ថុ និង ពាណិជ្ជកម្មនៅប្រទេសកម្ពុជានឹងគឺជាគុណសម្បត្តិមួយ។ អ្នកឯកទេសនឹងជួយធនាគារជាតិនៃកម្ពុជាក្នុងអំឡុងពេលចុះបំពេញការងារចំនួនពីរដង ក្នុងការផ្សព្វផ្សាយជាសាធារណៈនូវរបបឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់។

លើសពីនេះទៀត អ្នកឯកទេសនឹងបំពេញភារកិច្ចដូចខាងក្រោមនេះ

(i) ប្រសិនបើចាំបាច់ ជួយដល់ធនាគារជាតិនៃកម្ពុជាក្នុងអំឡុងពេលពិភាក្សានៅរដ្ឋសភាជាតិលើសេចក្តីព្រាងច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់បច្ចុប្បន្ន។

(ii) ធ្វើសិក្ខាសាលាផ្សព្វផ្សាយដើម្បីពន្យល់ច្បាប់ថ្មីនេះ និង បទប្បញ្ញត្តិអនុវត្តច្បាប់នេះ។ សហការជាមួយអ្នកឯកទេសបណ្តុះបណ្តាល ក្នុងការរៀបចំវគ្គសិក្សាច្បាប់ពាណិជ្ជកម្ម។

(iii) ផ្តល់ការបណ្តុះបណ្តាលជូនដល់បុគ្គលិកនៃអង្គភាពប្រតិបត្តិការធនាគារនិងទូទាត់នៃធនាគារជាតិនៃកម្ពុជា ស្តីអំពីច្បាប់ថ្មីនេះ និង បទប្បញ្ញត្តិអនុវត្តន៍។

(iv) តាមរយៈសិក្ខាសាលានៅក្នុងចំណុច (ii) ពិភាក្សានិងរាយការណ៍ពីភាពទន់ខ្សោយនៅក្នុងប្រព័ន្ធនិង/ឬនីតិវិធីទូទាត់និងផាត់ទាត់ដែលមានស្រាប់ ដែលធនាគារជាតិនៃកម្ពុជា និង អនុវិស័យធនាគារបានប្រើប្រាស់ ដោយរួមទាំងលើកជាដំណោះស្រាយផងដែរ។

(v) ផ្តល់របាយការណ៍ទាំងអស់តាមការកំណត់ជូនដល់ ធនាគារជាតិនៃកម្ពុជា និង ធនាគារអភិវឌ្ឍន៍អាស៊ី។

### គ. **អ្នកឯកទេសច្បាប់ខាងត្រួតពិនិត្យវិស័យធានារ៉ាប់រង** (៥ ខែ មានចន្លោះពេល)

១០. អ្នកឯកទេសអន្តរជាតិខាងធានារ៉ាប់រង ត្រូវមានចំណេះដឹងនិងបទពិសោធន៍ជាក់ស្តែងច្រើននៅក្នុងការងារត្រួតពិនិត្យនិងបទប្បញ្ញត្តិវិស័យធានារ៉ាប់រង ជាពិសេសនៅក្នុងការរៀបចំនិងការបង្ខំឱ្យអនុវត្តបទប្បញ្ញត្តិប្រុងប្រយ័ត្ន។ ការយល់ដឹងពីក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិសម្រាប់វិស័យធានារ៉ាប់រងនៅប្រទេសកម្ពុជានិងតំបន់គឺជាគុណសម្បត្តិមួយ។ អ្នកឯកទេសនឹងជួយនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងអំឡុងពេលចុះបំពេញការងារចំនួនពីរ ដើម្បីលើកកំពស់សមត្ថភាពត្រួតពិនិត្យរបស់បុគ្គលិកនៅនាយកដ្ឋាន។ លើសពីនេះទៀត អ្នកឯកទេសនឹងត្រូវបំពេញភារកិច្ចដូចខាងក្រោមនេះ

(i) បើមូលនិធិនៅមាន ត្រូវរៀបចំដំណើរទស្សនកិច្ចសិក្សាសម្រាប់បុគ្គលិកជាន់ខ្ពស់នៃអង្គភាពធានារ៉ាប់រង ទៅកាន់ប្រទេសជិតខាងមួយដើម្បីសង្កេតនិងទទួលបាននូវបទពិសោធន៍ជាក់ស្តែងអំពីរបៀបដែលនិយតករធានារ៉ាប់រងធ្វើការងារ។

(ii) ពិគ្រោះយោបល់ជាមួយអ្នករួមចំណែកពាក់ព័ន្ធ ដើម្បីរៀបចំយុទ្ធសាស្ត្រស្ថាប័ន (រួមមាន រចនាសម្ព័ន្ធស្ថាប័នតាមយថានុរូបមួយ) និងផែនការអភិវឌ្ឍន៍ធុរកិច្ចដើម្បីពង្រឹងប្រសិទ្ធភាពរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្នុងនាមជាអ្នកត្រួតពិនិត្យវិស័យធានារ៉ាប់រង។ កិច្ចការងារនេះត្រូវមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

(iii) ពិនិត្យឡើងវិញនូវបទប្បញ្ញត្តិប្រុងប្រយ័ត្នពាក់ព័ន្ធសម្រាប់វិស័យធានារ៉ាប់រង និងបែបបទឯកសារការងារ និង ពិភាក្សាជាមួយបុគ្គលិកដើម្បីកំណត់ចន្លោះប្រហោងនៅក្នុងបទប្បញ្ញត្តិនិងការអនុវត្តបទប្បញ្ញត្តិទាំងនេះ និង តម្រូវការខាងការបណ្តុះបណ្តាលរបស់បុគ្គលិកត្រួតពិនិត្យវិស័យធានារ៉ាប់រង។ ផ្តល់អនុសាសន៍លើការកែលំអដើម្បីស្នើឡើងនូវសេចក្តីណែនាំប្រុងប្រយ័ត្នវិស័យធានារ៉ាប់រងដែលផ្អែកលើហានិភ័យ។

(iv) ផ្អែកលើលទ្ធផលពីចំណុច (iii) រៀបចំសេចក្តីណែនាំនិង/ឬនីតិវិធីដើម្បីជួយបុគ្គលិកត្រួតពិនិត្យវិស័យធានារ៉ាប់រង ក្នុងការអនុវត្តមុខងារត្រួតពិនិត្យឯកសារ និងត្រួតពិនិត្យនៅនឹងកន្លែងរបស់ខ្លួន។

(v) ផ្អែកលើលទ្ធផលពីចំណុច (iii) និង (iv) ផ្តល់ការបណ្តុះបណ្តាល និង ការណែនាំនៅកន្លែងការងារ ដើម្បីជួយបុគ្គលិកក្នុងការអនុវត្តន៍ការណែនាំនិងនីតិវិធីត្រួតពិនិត្យវិស័យធានារ៉ាប់រងដែលរួមមានយ៉ាងតិចបំផុត ការពិនិត្យវាយតម្លៃលើអធិការកិច្ចនៅនឹងកន្លែងចំនួនពីរ។

(viii) ផ្តល់របាយការណ៍ចាប់ផ្តើមដំបូង របាយការណ៍បណ្តោះអាសន្ន និង ចុងក្រោយ តាមការកំណត់ ជូនដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ធនាគារអភិវឌ្ឍន៍អាស៊ី។

### ឃ. អ្នកឯកទេសខាងកំណែទម្រង់សាជីវកម្មធានារ៉ាប់រង (២.៥ ខែ មានចន្លោះពេល)

១១. អ្នកឯកទេសអន្តរជាតិខាងកំណែទម្រង់សាជីវកម្មធានារ៉ាប់រង ត្រូវមានចំណេះដឹងច្រើនខាងវិស័យធានារ៉ាប់រង និង បទពិសោធន៍ជាក់ស្តែងលើកំណែទម្រង់សាជីវកម្ម។ ការយល់ដឹងពីក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិនៃវិស័យធានារ៉ាប់រង ក៏ដូចជានីតិវិធីកាត់បន្ថយបុគ្គលិកនៅប្រទេសកម្ពុជាគឺជាគុណសម្បត្តិមួយ។ អ្នកឯកទេសអន្តរជាតិខាងកំណែទម្រង់សាជីវកម្មធានារ៉ាប់រង ក្នុងដំណើរចុះបំពេញការងារចំនួនពីរដង នឹង:

(i) ផ្តល់ការណែនាំដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រុមប្រឹក្សាភិបាល និង ប្រធាននៃក្រុមហ៊ុនកាមីនកូ ក្នុងការអនុវត្តន៍ផែនការកំណែទម្រង់ដែលបានអនុម័តរួចហើយសម្រាប់កាមីនកូ និង ធានាឱ្យបានថា ការងារនេះសម្រេចបានតាមកាលវិភាគអនុវត្តន៍ដែលបានអនុម័តរួចហើយ ។

(ii) លើកឡើងនូវជម្រើសដំណោះស្រាយនានា ដោយពិគ្រោះយោបល់យ៉ាងជិតដល់ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីដោះស្រាយបញ្ហាដែលបានពើបប្រទះក្នុងការអនុវត្តន៍និង

(iii) ផ្តល់របាយការណ៍ទាំងអស់ តាមការកំណត់ ជូនដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារអភិវឌ្ឍន៍អាស៊ី ។

ង. **អ្នកឯកទេសបណ្តុះបណ្តាលច្បាប់ពាណិជ្ជកម្ម** (២ ខែ មានចន្លោះពេល)

១២. អ្នកឯកទេសអន្តរជាតិខាងការបណ្តុះបណ្តាលត្រូវមានចំណេះដឹងច្រើនខាងច្បាប់ពាណិជ្ជកម្ម និងបទពិសោធន៍ជាក់ស្តែងនៅក្នុងការរៀបចំមេរៀនបណ្តុះបណ្តាលសម្រាប់ក្រុមគោលដៅ ។ ការយល់ដឹងពីក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិនៃវិស័យហិរញ្ញវត្ថុកម្ពុជាគឺជាគុណសម្បត្តិមួយ ។ អ្នកឯកទេស ក្នុងដំណើរចុះបំពេញការងារចំនួនពីរដង នឹងជួយក្រសួងពាណិជ្ជកម្មនៅក្នុងការរៀបចំវគ្គសិក្សាច្បាប់ពាណិជ្ជកម្មសម្រាប់ស្ថាប័នបណ្តុះបណ្តាលច្បាប់ជាគោលដៅ ។ វគ្គសិក្សានេះនឹងរួមមានគោលការណ៍ច្បាប់ដែលដកស្រង់ពីច្បាប់មានស្រាប់ និង សេចក្តីព្រាងច្បាប់ដែលបច្ចុប្បន្ននេះរដ្ឋាភិបាលកំពុងពិចារណា ។ បន្ថែមលើនេះ អ្នកឯកទេសអន្តរជាតិខាងការងារបណ្តុះបណ្តាល នឹងបំពេញភារកិច្ចខាងក្រោមនេះ:

(i) ជួយក្រសួងពាណិជ្ជកម្មក្នុងការទាក់ទងជាមួយស្ថាប័នបណ្តុះបណ្តាលច្បាប់ ដើម្បីដាក់បញ្ចូលវគ្គសិក្សាពាណិជ្ជកម្មនៅក្នុងកម្មវិធីសិក្សារបស់ស្ថាប័នទាំងនេះ ។ ប្រការនេះអាចមានទម្រង់ជាសិក្ខាសាលារយៈពេលខ្លីសម្រាប់ចៅក្រម មេធាវី និង ក្រឡាបញ្ជី ដើម្បីបង្កើត ការយល់ដឹងនិងតម្រូវការមេរៀនច្បាប់ពាណិជ្ជកម្ម ។

(ii) ផ្តល់របាយការណ៍ទាំងអស់ តាមការកំណត់ ជូនដល់ក្រសួងពាណិជ្ជកម្ម និង ធនាគារអភិវឌ្ឍន៍អាស៊ី ។

## ២. អ្នកពិគ្រោះការងារក្នុងស្រុក

ក. **អ្នកឯកទេសខាងត្រួតពិនិត្យវិស័យធានារ៉ាប់រង** (៧ ខែ មានចន្លោះពេល)

១៣. អ្នកឯកទេសនេះចាំបាច់ត្រូវមានចំណេះដឹងការងារខ្លះអំពីបទប្បញ្ញត្តិធានារ៉ាប់រង ការយល់ដឹងល្អ

អំពីអនុវិស័យធានារ៉ាប់រង និង ស្ទាត់ជំនាញខាងភាសាអង់គ្លេស។ បទពិសោធន៍ការងារជាមួយអង្គការអន្តរជាតិគឺជាគុណសម្បត្តិមួយ។ លើសពីនេះទៀត អ្នកឯកទេសនេះនឹងបំពេញភារកិច្ចដូចខាងក្រោមនេះ:

(i) ជួយអ្នកឯកទេសអន្តរជាតិខាងការត្រួតពិនិត្យវិស័យធានារ៉ាប់រងនៅក្នុងគ្រប់ទិដ្ឋភាពទាំង អស់នៃភារកិច្ចការងាររបស់គាត់ រួមទាំងការរៀបចំការជួបប្រជុំនៅក្នុងប្រទេសផងដែរ។

(ii) ក្រោមការណែនាំរបស់អ្នកឯកទេសអន្តរជាតិ ត្រូវប្រមូលនិងវិភាគព័ត៌មាននិងទិន្នន័យចាំបាច់ និងធានាឱ្យបានថា របាយការណ៍គឺមានជាភាសាអង់គ្លេស។

(iii) ធ្វើជាអ្នកបកប្រែជូនអ្នកឯកទេសអន្តរជាតិ និង បេសកកម្មធនាគារអភិវឌ្ឍន៍អាស៊ីនៅពេលណាចាំបាច់។

(iv) ជួយអ្នកឯកទេសអន្តរជាតិក្នុងការរៀបចំរបាយការណ៍ចាំបាច់ទាំងឡាយសម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ធនាគារអភិវឌ្ឍន៍អាស៊ី ។

ខ. **អ្នកឯកទេសវិស័យធានារ៉ាប់រង** (៤ ខែ មានចន្លោះពេល)

១៤. អ្នកឯកទេសនេះចាំបាច់ត្រូវមានចំណេះដឹងការងារខ្លះអំពីប្រតិបត្តិការធានារ៉ាប់រង ការយល់ដឹងល្អអំពីអនុវិស័យធានារ៉ាប់រង និង ស្ទាត់ជំនាញខាងភាសាអង់គ្លេស។ បទពិសោធន៍ការងារជាមួយអង្គការអន្តរជាតិគឺជាគុណសម្បត្តិមួយ។ លើសពីនេះទៀត អ្នកឯកទេសនេះនឹងបំពេញភារកិច្ចដូចខាងក្រោមនេះ:

(i) ជួយអ្នកឯកទេសអន្តរជាតិខាងកំណែទម្រង់សាជីវកម្មវិស័យធានារ៉ាប់រងនៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃភារកិច្ចការងាររបស់គាត់ រួមទាំងការរៀបចំការជួបប្រជុំនៅក្នុងប្រទេសផងដែរ។

(ii) ក្រោមការណែនាំរបស់អ្នកឯកទេសអន្តរជាតិ ប្រមូលនិងវិភាគព័ត៌មាននិងទិន្នន័យចាំបាច់ និងធានាឱ្យបានថា របាយការណ៍គឺមានជាភាសាអង់គ្លេស។

(iii) ធ្វើជាអ្នកបកប្រែជូនអ្នកឯកទេសអន្តរជាតិ និង ក្រុមបេសកកម្មធនាគារអភិវឌ្ឍន៍អាស៊ីនៅពេលណាចាំបាច់។

(iv) ជួយអ្នកឯកទេសអន្តរជាតិក្នុងការរៀបចំរបាយការណ៍ចាំបាច់ទាំងឡាយសម្រាប់ក្រសួង

សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ធនាគារអភិវឌ្ឍន៍អាស៊ី ។

គ. **អ្នកឯកទេសខាងបណ្តុះបណ្តាលច្បាប់** ( ៣ ខែ មានចន្លោះពេល)

១៥. អ្នកឯកទេសនេះចាំបាច់ត្រូវមានចំណេះដឹងការងារខ្លះអំពីច្បាប់និងពាណិជ្ជកម្ម ការយល់ដឹងល្អអំពីវិស័យហិរញ្ញវត្ថុកម្ពុជា និង ស្ទាត់ជំនាញខាងភាសាអង់គ្លេស ។ បទពិសោធន៍ការងារជាមួយអង្គការអន្តរជាតិគឺជាគុណសម្បត្តិមួយ ។ លើសពីនេះទៀត អ្នកឯកទេសនេះនឹងបំពេញភារកិច្ចដូចខាងក្រោមនេះ:

(i) ជួយអ្នកឯកទេសអន្តរជាតិខាងការបណ្តុះបណ្តាលច្បាប់ពាណិជ្ជកម្ម នៅក្នុងគ្រប់ទិដ្ឋភាព ទាំងអស់នៃភារកិច្ចការងាររបស់គាត់ រួមទាំងការរៀបចំការជួបប្រជុំ និង សិក្ខាសាលានៅក្នុងប្រទេសផងដែរ ។

(ii) ក្រោមការណែនាំរបស់អ្នកឯកទេសអន្តរជាតិ ប្រមូលនិងវិភាគព័ត៌មាននិងទិន្នន័យចាំបាច់និងធានាឱ្យបានថា របាយការណ៍ស្តីពីព័ត៌មាននិងទិន្នន័យទាំងនេះគឺមានជាភាសាអង់គ្លេស ។

(iii) ធ្វើជាអ្នកបកប្រែជូនអ្នកឯកទេសអន្តរជាតិ និង បេសកកម្មធនាគារអភិវឌ្ឍន៍អាស៊ីនៅពេលណាចាំបាច់ ។

(iv) ជួយអ្នកឯកទេសអន្តរជាតិក្នុងការរៀបចំរបាយការណ៍ចាំបាច់ទាំងឡាយសម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ធនាគារអភិវឌ្ឍន៍អាស៊ី ។

## សមិទ្ធផលនៃអនុកម្មវិធីទី ១ និងទី ២ និង សំណើសកម្មភាពសម្រាប់អនុកម្មវិធីទី ៣

| អនុកម្មវិធីទី ១ | ស្ថានភាពនៃ អនុកម្មវិធីទី១ | អនុកម្មវិធីទី ២ | ស្ថានភាពនៃ អនុកម្មវិធីទី ២ | សំណើសកម្មភាពសម្រាប់អនុកម្មវិធីទី ៣ |
|---|---|---|---|---|
| **១. អនុវិស័យធនាគារ** | | **១. អនុវិស័យធនាគារ** | | **១. កិច្ចអភិវឌ្ឍន៍អនុវិស័យធនាគារ** |
| ក. ពង្រឹងការត្រួតពិនិត្យធនាគារ / បទប្បញ្ញត្តិប្រុងប្រយ័ត្ន | | ក. អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអនុវិស័យ ធនាគារ និង សំណាញ់សុវត្ថិភាព | | ក. អភិវឌ្ឍនហេដ្ឋារចនាសម្ព័ន្ធអនុវិស័យ ធនាគារ |
| ធនាគារជាតិនៃកម្ពុជាត្រូវសម្រួលឱ្យស្របស៊ីគ្នារវាង បទប្បញ្ញត្តិប្រុងប្រយ័ត្នចាស់ជាមួយនឹង បទប្បញ្ញត្តិថ្មី និង ចេញសេចក្តីណែនាំបំភ្លឺជូនដល់ធនាគារពាណិជ្ជ ។ | បានសម្រេច | ធនាគារជាតិនៃកម្ពុជាត្រូវអនុម័តសេចក្តីណែនាំ សម្រាប់រៀបចំឱ្យមានការផ្លាស់ប្តូរព័ត៌មានឥណទាន ក្នុងចំណោមសមាជិកនៃសមាគមធនាគារិក ។ ធនាគារជាតិនៃកម្ពុជានិងសមាគមធនាគារិក ត្រូវបង្កើតឱ្យចំណាត់ការបែបនេះចេញជារូបរាង ។ | បានសម្រេច | |
| ធនាគារជាតិនៃកម្ពុជាដាក់បំពេញបុគ្គលិកផ្នែកត្រួតពិនិត្យនៅនឹងកន្លែងនៃនាយកដ្ឋានត្រួតពិនិត្យ ធនាគារឱ្យបានពេញលេញ ដែលអាចទទួលយកបាន ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ។ | បានសម្រេច | ធនាគារជាតិនៃកម្ពុជាត្រូវអនុម័តប្លង់គណនីធនាគារ ឯកភាពនិង វិធានរាយការណ៍សម្រាប់ធនាគារពាណិជ្ជ ដែលមានសង្គតិភាពជាមួយនឹងស្តង់ដារគណនេយ្យ អន្តរជាតិ (IAS) ។ | បានសម្រេច | |
| ធនាគារជាតិនៃកម្ពុជាអនុម័តនីតិវិធីជាផ្លូវការ ដើម្បី សុំយោបល់ពីវិស័យឯកជនលើសំណើកែប្រែ ឬ | បានសម្រេច | | | |

| អនុកម្មវិធីទី ១ | ស្ថានភាពនៃ អនុកម្មវិធីទី១ | អនុកម្មវិធីទី ២ | ស្ថានភាពនៃ អនុកម្មវិធីទី ២ | សំណើសកម្មភាពសម្រាប់អនុកម្មវិធីទី ៣ |
|---|---|---|---|---|
| ការកែច្បាប់បទប្បញ្ញត្តិ នីតិវិធីនិងគោលនយោបាយ ដែលប៉ះពាល់ដល់អនុវិស័យធនាគារ ។ | | ធនាគារជាតិនៃកម្ពុជាអនុវត្តប្លង់គណនីធនាគារឯកភាព និង វិធានរាយការណ៍សម្រាប់ធនាគារពាណិជ្ជ ដែលមានសង្គតិភាពជាមួយនឹងស្តង់ដារគណនេយ្យអន្តរជាតិ (IAS) ចំពោះធនាគារអភិវឌ្ឍន៍ជនបទ និង ធនាគារឯកទេសដទៃទៀត ។ | បានសម្រេច | |
| ធនាគារជាតិនៃកម្ពុជា ត្រូវអនុម័តនីតិវិធីត្រួតពិនិត្យ និង អធិការកិច្ច រួមទាំងការធ្វើឱ្យទៅជាស្តង់ដារនូវរបាយការណ៍ទាំងឡាយ ដែលធនាគារពាណិជ្ជត្រូវដាក់ជូន វាលែងតែមានការបញ្ជាក់ផ្សេងពីនេះនៅក្នុងបទប្បញ្ញត្តិធនាគារជាតិនៃកម្ពុជា ។ នីតិវិធីទាំងនេះ ក៏នឹងត្រូវបានអនុវត្តផងដែរ ចំពោះស្ថាប័នមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណទាំងឡាយ ។ | បានសម្រេច | ក្រសួងពាណិជ្ជកម្មដាក់ជូនរដ្ឋសភាជាតិនូវសេចក្តីព្រាងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ។ | បានសម្រេច | ការអនុម័តច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដោយរដ្ឋសភាជាតិ ។ |
| | | ក្រសួងពាណិជ្ជកម្មអនុម័តផែនការដើម្បីបង្កើតប្រព័ន្ធចុះបញ្ជីសាធារណៈមួយសម្រាប់ប្រតិបត្តិការដែលមានកិច្ចធានា ដែលធនាគារអភិវឌ្ឍន៍អាស៊ីអាចទទួលយកបាន ។ | បានសម្រេច | ក្រសួងពាណិជ្ជកម្មបង្កើតប្រព័ន្ធចុះបញ្ជីសាធារណៈមួយសម្រាប់ប្រតិបត្តិការដែលមានកិច្ចធានា ។ |
| ធនាគារជាតិនៃកម្ពុជា ត្រូវអនុម័តប្រព័ន្ធកែតម្រូវសកម្មភាពបន្ទាន់មួយសម្រាប់ធនាគារពាណិជ្ជ ដែលធនាគារអភិវឌ្ឍន៍អាស៊ី អាចទទួលយកបាន ។ ប្រព័ន្ធដូចគ្នាមួយនឹងត្រូវបានអនុវត្ត ចំពោះស្ថាប័នមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណទាំងឡាយ ដោយមានការកែប្រែស្តង់ដារលើភាពមានដើមទុន | បានសម្រេច | **ខ. ការកសាងសមត្ថភាព**<br>ធនាគារជាតិនៃកម្ពុជាធានាឱ្យបានថា មជ្ឈមណ្ឌលសិក្សាធនាគារ បង្កើតវគ្គសិក្សាធនាគារកណ្តាលមួយសម្រាប់បុគ្គលិកអាជីពរបស់ ធនាគារជាតិនៃកម្ពុជា | បានសម្រេច | ធនាគារជាតិនៃកម្ពុជាបង្កើតអង្គភាពមួយ និងធ្វើការងារត្រៀមដែលចាំបាច់សម្រាប់ |

| អនុកម្មវិធីទី ១ | ស្ថានភាពនៃអនុកម្មវិធីទី១ | អនុកម្មវិធីទី ២ | ស្ថានភាពនៃអនុកម្មវិធីទី ២ | សំណើសកម្មភាពសម្រាប់អនុកម្មវិធីទី ៣ |
|---|---|---|---|---|
| គ្រប់គ្រាន់។ | | ដែលរួមមានកម្មវិធី បណ្តុះបណ្តាលជាកាតព្វកិច្ចមួយសម្រាប់បុគ្គលិកអាជីពចាប់ផ្តើមការងារតំបូង។ | | ឈានទៅបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុដែលទទួលបន្ទុកលើការប្រឆាំងការលាងសំអាតប្រាក់ និង ប្រយុទ្ធនឹងហិរញ្ញប្បទានភេរវកម្ម។ |
| ធនាគារជាតិនៃកម្ពុជាត្រូវអនុម័តបទប្បញ្ញត្តិប្រឆាំងការលាងសំអាតប្រាក់ វាលែងតែមានការបញ្ជាក់ផ្សេងពីនេះនៅក្នុងបទប្បញ្ញត្តិធនាគារជាតិនៃកម្ពុជា។ បទប្បញ្ញត្តិនេះក៏នឹងត្រូវយកទៅអនុវត្តផងដែរចំពោះស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលមានអាជ្ញាប័ណ្ណទាំងឡាយ។ | បានសម្រេច | | | **ខ. កិច្ចអភិវឌ្ឍន៍ច្បាប់ពាណិជ្ជកម្ម និងការកសាងសមត្ថភាព** |
| | | | | ការអនុម័តច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្មដោយរដ្ឋសភាជាតិ។ |
| **ខ. ការកសាងសមត្ថភាព** | | | | |
| ធនាគារជាតិនៃកម្ពុជាបង្កើតមជ្ឈមណ្ឌលសិក្សាធនាគារជាសាខាមួយនៃធនាគារជាតិនៃកម្ពុជាដោយមានការគ្រប់គ្រងនិងគណនីដាច់ដោយឡែកពីគ្នា។ | បានសម្រេច | | | ការដាក់ច្បាប់ស្តីពីធនក្ស័យជូនរដ្ឋសភាជាតិ។ |
| | | | | ក្រសួងពាណិជ្ជកម្មធានាឱ្យបាននូវការផ្សព្វផ្សាយច្បាប់ពាណិជ្ជកម្មតាមអ៊ិនធឺណែត។ |
| ធនាគារជាតិនៃកម្ពុជាធានាឱ្យបានថា គណៈគ្រប់គ្រងនៃធនាគារពាណិជ្ជកម្មក្រៅប្រទេស នឹងអនុម័តនូវកម្មវិធីបណ្តុះបណ្តាលបុគ្គលិកដ៏ពេញលេញមួយ | បានសម្រេច | | | ក្រសួងពាណិជ្ជកម្មសហការជាមួយគ្រឹះស្ថានច្បាប់ពាក់ព័ន្ធ ដើម្បីរៀបចំកម្មវិធីសិក្សាច្បាប់ |

| អនុកម្មវិធីទី ១ | ស្ថានភាពនៃអនុកម្មវិធីទី១ | អនុកម្មវិធីទី ២ | ស្ថានភាពនៃអនុកម្មវិធីទី ២ | សំណើសកម្មភាពសម្រាប់អនុកម្មវិធីទី ៣ |
|---|---|---|---|---|
| រួមមានគណនេយ្យ ការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងទ្រព្យសកម្មនិង ទ្រព្យអកម្ម និង ប្រព័ន្ធព័ត៌មានគ្រប់គ្រងមួយ ។ | | | | ពាណិជ្ជកម្មដែលផ្អែកលើច្បាប់ពាណិជ្ជកម្មថ្មីៗទាំងឡាយ ដើម្បីបណ្តុះបណ្តាលចៅក្រម មេធាវី និង ក្រឡាបញ្ជី ។ |
| **២. អនុវិស័យធានារ៉ាប់រង**<br>**ក. បង្កើតក្របខ័ណ្ឌត្រួតពិនិត្យនិង/ឬក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់កិច្ចអភិវឌ្ឍន៍វិស័យធានារ៉ាប់រង**<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបង្កើតអង្គភាពត្រួតពិនិត្យវិស័យធានារ៉ាប់រងមួយនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។<br><br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធានាឱ្យបាននូវការចេញអនុក្រឹត្យមួយ ដើម្បីអនុវត្តច្បាប់ស្តីពីធានារ៉ាប់រង ។ | បានសម្រេច<br><br>បានសម្រេច | **២. អនុវិស័យធានារ៉ាប់រង**<br>**ក. បង្កើតក្របខ័ណ្ឌសម្រាប់កាតព្វកិច្ចធានារ៉ាប់រង**<br>ក្រសួងហិរញ្ញវត្ថុ ដោយពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធដទៃទៀត អនុម័តប្រកាសអន្តរក្រសួងដើម្បីកិច្ចអភិវឌ្ឍន៍កាតព្វកិច្ចធានារ៉ាប់រង ។<br><br>**ខ. ការលើកកំពស់កិច្ចអភិវឌ្ឍន៍វិស័យឯកជន**<br>ក្រសួងហិរញ្ញវត្ថុបង្កើតសម្ព័ន្ធអាជីវកម្មរវាងក្រុមហ៊ុនធានារ៉ាប់រងរដ្ឋ និង ក្រុមហ៊ុនធានារ៉ាប់រងឯកជន ។ | បានសម្រេច<br><br>សម្រេចបានខ្លះ និងត្រូវបានរំកិលទៅក្នុងអនុកម្ម-វិធីទី៣ | **២. អនុវិស័យធានារ៉ាប់រង**<br>**ក. ពង្រឹងសមត្ថភាពរបស់និយតករ**<br>ក្រសួងហិរញ្ញវត្ថុពិនិត្យឡើងវិញ កែសម្រួលជាថ្មី និង អនុវត្តបទប្បញ្ញត្តិប្រុងប្រយ័ត្នដើម្បីលើកកំពស់សាធនភាព សន្ទនីយភាព និង ល័ក្ខខ័ណ្ឌអភិបាលកិច្ចសាជីវកម្មល្អ និង ផ្តល់ការទ្រទ្រង់ខាងជំនួយ បច្ចេកទេសជូនដល់និយតករធានារ៉ាប់រង ។<br><br>**ខ. ជំរុញការចូលរួមរបស់វិស័យឯកជនក្នុងអនុវិស័យធានារ៉ាប់រង** |

| អនុកម្មវិធីទី ១ | ស្ថានភាពនៃអនុកម្មវិធីទី១ | អនុកម្មវិធីទី ២ | ស្ថានភាពនៃអនុកម្មវិធីទី ២ | សំណើសកម្មភាពសម្រាប់អនុកម្មវិធីទី ៣ |
|---|---|---|---|---|
| | | | | ក្រសួងហិរញ្ញវត្ថុអនុវត្តសកម្មភាពគន្លឹះទាំងឡាយនៃផែនការធ្វើកំណែទម្រង់កាមីនកូតាមការឯកភាពជាមួយធនាគារអភិវឌ្ឍន៍អាស៊ី សំដៅវិនិយោគលក់ចេញនូវភាគហ៊ុនរបស់រដ្ឋាភិបាលឱ្យបានយ៉ាងឆាប់បំផុត ។ |
| **៣. ទីផ្សាររូបិយវត្ថុ/ទីផ្សារអន្តរធនាគារ**<br>**ក. បង្កើតកិច្ចព្រមព្រៀងទីផ្សារអន្តរធនាគារ**<br>ធនាគារជាតិទទួលស្គាល់សមាគមធនាគារិក ជាស្ថាប័ននិយ័តកម្មស្វ័យ័តមួយ<br>- លក្ខន្តិកៈរបស់សមាគមដែលត្រូវបានឯកភាពរួមមានបទប្បញ្ញត្តិដើម្បីបង្កើតកិច្ចព្រមព្រៀងទីផ្សារអន្តរធនាគារ និង កិច្ចព្រមព្រៀងសម្រាប់ការផ្លាស់ប្តូរព័ត៌មានឥណទាន ក្នុងចំណោមសមាជិកនៃសមាគមធនាគារិក និង វិទ្យាស្ថានធនាគារសម្រាប់បុគ្គលិកធនាគារឯកជន ។ | បានសម្រេច | **៣. ទីផ្សាររូបិយវត្ថុ/ទីផ្សារអន្តរធនាគារ**<br>ធនាគារជាតិដាក់ជូនរដ្ឋសភាជាតិនូវសេចក្តីព្រាងច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់ ។ | បានសម្រេច | **៣. ទីផ្សាររូបិយវត្ថុ/ទីផ្សារអន្តរធនាគារ**<br>**ក. ក្របខ័ណ្ឌច្បាប់សម្រាប់កិច្ចអភិវឌ្ឍន៍ទីផ្សាររូបិយវត្ថុ**<br>រដ្ឋសភាជាតិអនុម័តច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់ ។<br><br>ធនាគាជាតិនៃកម្ពុជាត្រូវធ្វើសេចក្តីព្រាង និងអនុម័តបទប្បញ្ញត្តិសំរាប់ការអនុវត្តច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់ ។ |

| អនុកម្មវិធីទី ១ | ស្ថានភាពនៃអនុកម្មវិធីទី១ | អនុកម្មវិធីទី ២ | ស្ថានភាពនៃអនុកម្មវិធីទី ២ | សំណើសកម្មភាពសម្រាប់អនុកម្មវិធីទី ៣ |
|---|---|---|---|---|
| - ធនាគារជាតិនៃកម្ពុជា និងសមាគមធនាគារិក ត្រូវបង្កើតក្រុមការងារមួយដើម្បីអភិវឌ្ឍ កិច្ចព្រមព្រៀងទីផ្សារអន្តរធនាគារ កិច្ចព្រមព្រៀងសម្រាប់ការផ្លាស់ប្តូរព័ត៌មានឥណទាន ក្នុងចំណោមសមាជិកនៃសមាគមធនាគារិក និង វិទ្យាស្ថានធនាគារមួយ ។ | | | | |
| **៤. ហេដ្ឋារចនាសម្ព័ន្ធគណនេយ្យ និង សវនកម្ម និង ច្បាប់**<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដាក់ជូនរដ្ឋសភាជាតិនូវសេចក្តីព្រាងច្បាប់ស្តីពីគណនីសហគ្រាស សវនកម្មគណនីសហគ្រាស និង វិជ្ជាជីវៈគណនេយ្យ ។<br><br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអនុម័តស្តង់ដារគណនេយ្យអន្តរជាតិ និង ស្តង់ដារសវនកម្ម អន្តរជាតិ ដែលនឹងត្រូវបានអនុវត្ត ក្រោយពេល អនុម័តច្បាប់ស្តីពីគណនីសាជីវកម្ម សវនកម្ម | បានសម្រេច<br><br>បានសម្រេច | **៤. ហេដ្ឋារចនាសម្ព័ន្ធគណនេយ្យ និង សវនកម្ម និង ច្បាប់**<br>ការអនុម័តច្បាប់ស្តីពីគណនីសហគ្រាស សវនកម្មគណនីសហគ្រាស និង វិជ្ជាជីវៈគណនេយ្យ ។<br><br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអនុម័តអនុក្រឹត្យ ដើម្បីអនុវត្តស្តង់ដារគណនេយ្យអន្តរជាតិ និង ស្តង់ដារសវនកម្មអន្តរជាតិ ចំពោះក្រុមហ៊ុនទាំងអស់ (រួមទាំងក្រុមហ៊ុនធានារ៉ាប់រង) ដែលប្រកបអាជីវកម្មនៅកម្ពុជា និងដើម្បីបង្កើតក្រុមប្រឹក្សា | បានសម្រេច<br><br>បានសម្រេច | **៤. កិច្ចអភិវឌ្ឍន៍ការអនុវត្តន៍គណនេយ្យ និង សវនកម្ម** |

| អនុកម្មវិធីទី ១ | ស្ថានភាពនៃអនុកម្មវិធីទី១ | អនុកម្មវិធីទី ២ | ស្ថានភាពនៃអនុកម្មវិធីទី ២ | សំណើសកម្មភាពសម្រាប់អនុកម្មវិធីទី ៣ |
|---|---|---|---|---|
| គណនីសាជីវកម្ម និង វិជ្ជាជីវៈគណនេយ្យ ។<br><br>ក្រសួងពាណិជ្ជកម្មដាក់ជូនរដ្ឋសភាជាតិនូវសេចក្តីព្រាងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ។ | បានសម្រេច | គណនេយ្យជាតិ ដើម្បីកំណត់ និងបកស្រាយស្តង់ដារទាំងនេះ ។<br><br>ការអនុម័តច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ។<br><br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបង្កើតសមាគមគណនេយ្យករ និង សវនករ ដែលរួមមាន:<br>(១) ការអនុម័តក្រមសីលធម៌ដែលគោរពតាមល័ក្ខខ័ណ្ឌនៃសហព័ន្ធអន្តរជាតិនៃគណនេយ្យករ និង<br>(២) ការបង្កើតគណៈកម្មាធិការអប់រំ និង សីលធម៌នៅក្នុងសមាគមនេះ ។ | បានសម្រេច<br><br>បានសម្រេច | **ក. ការគាំទ្រសមត្ថភាពដល់កិច្ចអភិវឌ្ឍន៍សមជិកអាជីពនៃ KICPAA**<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធានាឱ្យបាននូវការជួយឧបត្ថម្ភខាងហិរញ្ញវត្ថុចំពោះអាហារូបករណ៍យ៉ាងតិចបំផុតចំនួន ៧០នាក់ក្នុងមួយឆ្នាំ សម្រាប់កិច្ចអភិវឌ្ឍន៍ សមាជិកអាជីពនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ។ |

**សេចក្តីបញ្ជាក់:** ឯកសារនេះត្រូវបានប្រែសម្រួលពីឯកសារដើមជាភាសាអង់គ្លេសដែលជាភាសាផ្លូវការតែមួយគត់របស់ធនាគារអភិវឌ្ឍន៍អាស៊ី។